ព្រឹត្តិបត្រព័ត៌មាន

# គណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ

# NGO Committee on the Rights of the Child

# NGOCRC

ឆ្នាំទី៤ លេខ១១ ខែកក្កដា_កញ្ញា ឆ្នាំ២០០៦

មាតិកា ទំព័រ

គណៈកម្មាធិការប្រតិបត្តិអាណត្តិថ្មីរបស់គ.អ.ស.ក....................១

សិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងរបាយការស្តីពីការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិស្តីពី...........១

សិក្ខាសាលាស្តីពីការបង្កើតកំរងសំនួរ និងការសរសេររបាយការណ៍.............១

ពិធីប្រគល់ប័ណ្ណសរសើរការងារជូនគណៈកម្មាធិការប្រតិបត្តិទើបផុត.......៣

របាយការណ៍ស្តីពីការរំលោភបំពានលើកុមារក្នុងត្រីមាសទី៣ឆ្នាំ២០០៦.........៤

សិក្ខាសាលាស្តីពីការបញ្ជ្រាបចំណេះដឹងផ្នែកសិទ្ធិកុមារដល់មន្ត្រីសុខាភិ..........៦

កំណាព្យ កុមារយ៉ាប់យ៉ឺន............១២

កំណាព្យ ការជួញដូរកុមារ...........១២

## គណៈកម្មាធិការប្រតិបត្តិអាណត្តិថ្មីរបស់គ.អ.ស.ក

សមាជិកគណៈកម្មាធិការប្រតិបត្តិអាណត្តិថ្មីរបស់គណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ (គ.អ.ស.ក)ចំនួន៥នាក់ត្រូវបានជ្រើសរើសតាមរយៈការបោះឆ្នោតកាលពីថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៦ នៅអគ្គលេខាធិការដ្ឋានគ.អ.ស.ក។ សមាជិកគណៈកម្មាធិការប្រតិបត្តិថ្មីរួមមាន **លោក មាស សំណាង** ជាប្រធាន **លោក ម៉ិច សុខា** ជាអនុប្រធាន **កញ្ញា លី សុធាវី** ជាលេខាធិការ **លោកស្រី ថូ ថារី** ជាហេរញ្ញិក និង**លោក ព្រុំ ធី** ជាសមាជិក។



សំលេងឆ្នោតត្រូវបានប្រកាស

**លោក មាស សំណាង** ជានាយករងទទួលបន្ទុកផ្នែករដ្ឋបាលនៃអង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា (LAC) ហើយដែលបានជាប់ឆ្នោតជាប្រធានគណៈកម្មាធិការប្រតិបត្តិថ្មីនេះ មានប្រសាសន៍ថា

តទៅទំព័រទី២

## សិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងរបាយការណ៍ស្តីពីការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ នៅកម្ពុជាឆ្នាំ២០០០_២០០៥

សិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងរបាយការណ៍ស្តីពីការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារនៅកម្ពុជាឆ្នាំ២០០០_២០០៥ បានធ្វើឡើងថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០០៦ នៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាដែលមាន

តទៅទំព័រទី៥

## សិក្ខាសាលាស្តីពីការបង្កើតកំរងសំនួរ និងការសរសេររបាយការណ៍



សិក្ខាសាលាស្តីពីការបង្កើតកំរងសំនួរ និងការសរសេររបាយការណ៍ត្រូវបានរៀបចំដោយគណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ

តទៅទំព័រទី១០

តមកពីទំព័រទី១



លោកធ្លាប់បានចូលរួមការងារជាអនុប្រធានគណៈកម្មាធិការប្រតិបត្តិរបស់គ.អ.ស.ករយៈពេលបីឆ្នាំមកហើយ ហើយលោកប្ដេជ្ញាក្នុងឱកាសមុនការបោះឆ្នោតថា ប្រសិនបើលោកជាប់ឆ្នោតអាណត្តិថ្មី លោកនឹងផ្ដល់នូវការទទួលខុសត្រូវដដែលនូវអ្វីដែលលោកមានក្នុងរយៈពេល៣ឆ្នាំកន្លងទៅ នៅក្នុងគណៈកម្មាធិការដើម្បីពង្រឹងគ.អ.ស.ក ក៏ដូចជាពង្រឹងសមត្ថភាពអង្គការសមាជិករបស់គ.អ.ស.ក។ ហើយសំខាន់បំផុតនោះ លោកនឹងទំនាក់ទំនងជាមួយសមាជិកគណៈកម្មាធិការប្រតិបត្តិអាណត្តិថ្មី និងសហប្រតិបត្តិការដើម្បីពង្រឹងការងាររបស់គ.អ.ស.កឱ្យមានដំណើរការល្អទៅបាន។



**លោក ម៉ិច សុខា** នាយកប្រតិបត្តិនៃមណ្ឌលកុមារដើម្បីសុភមង្គល (CCH) ដែលបានជាប់ឆ្នោតជាអនុប្រធានគណៈកម្មាធិការប្រតិបត្តិថ្មីមានប្រសាសន៍ថា លោកនឹងខិតខំធ្វើយ៉ាងណា ដើម្បីឱ្យគ.អ.ស.កក្លាយទៅជាមជ្ឈមណ្ឌលព័ត៌មានមួយដើម្បីកុមារ ដែលអាចទទួលយកបាន។ លោកសង្ឃឹមថា ការចូលរួមរបស់អង្គការសមាជិកនឹងដំណើរការគ.អ.ស.កទៅអនាគតឱ្យកាន់តែមានភាពល្អប្រសើរថែមទៀត។ លោកប្ដេជ្ញាថា «អ្វីដែលខ្ញុំអាចធ្វើទៅបាន ចំណេះដឹងដែលខ្ញុំបាទមាន និងធនធានដែលខ្ញុំអាចសំរេចបាន ខ្ញុំនឹងជួយដល់គ.អ.ស.ក ហើយទាំងការជួយស្វែងរកថវិកា ឬការផ្ដល់អនុសាសន៍ផ្សេងៗទៅដល់អង្គការសមាជិក ដែលមានការលំបាកក្នុងការស្វែងរកថវិកាដើម្បីឱ្យពួកគេទទួលបានថវិកាពីម្ចាស់មូលនិធិ»។



**កញ្ញា លី សុទ្ធារី** នាយិកាប្រតិបត្តិនៃមជ្ឈមណ្ឌលថែទាំសុខភាពកុមារ (HCC) ហើយដែលជាប់ឆ្នោតជាលេខាធិការ មានប្រសាសន៍ថា «ទោះបីជាអង្គការសមាជិករបស់គ.អ.ស.កភាគច្រើន នាងខ្ញុំនៅមិនទាន់បានស្គាល់អស់ក្ដី ប៉ុន្តែខ្ញុំនឹងតាំងចិត្តថា ខ្ញុំនឹងស្គាល់អង្គការសមាជិកនីមួយៗ ដោយធ្វើការសិក្សាអំពីគ្នា ថាតើអង្គការនីមួយៗធ្វើអ្វី ហើយយើងទាំងអស់គ្នារួមគ្នាអាចធ្វើអ្វីបានខ្លះដើម្បីជាប្រយោជន៍របស់កុមារក្នុងប្រទេសកម្ពុជា»។



**លោក ព្រំ ធី** នាយកប្រតិបត្តិនៃអង្គការខ្មែរទ្រទ្រង់សិទ្ធិកុមារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ(KTO) មានការតាំងចិត្តថា ១_នឹងបង្កើនឬរក្សានូវទំនាក់ទំនងល្អជាមួយស្ថាប័នរាជរដ្ឋាភិបាល អង្គការជាតិ_អន្តរជាតិ។ ២_ទំនាក់ទំនងឱ្យកាន់តែល្អប្រសើរ រួមសហការជាមួយគណៈកម្មាធិការប្រតិបត្តិ និងអង្គការសមាជិកក្នុងគោលបំណងកសាងយុទ្ធសាស្ត្រ និងគោលនយោបាយដើម្បីអភិវឌ្ឍគ.អ.ស.ក។ ៣_អនុម័តនូវគោលនយោបាយ និងកម្មវិធីការងារ ផ្ដល់យោបល់ និងចូលរួមពិនិត្យតាមដានការអនុវត្តការងាររបស់គ.អ.ស.ក។ ៤_ពង្រឹង និងរក្សាសាមគ្គីភាពក្នុងចំណោមអង្គការសមាជិកទាំងអស់របស់គ.អ.ស.ក។ ៥_ធានានូវកិច្ចសហប្រតិបត្តិការរវាងក្រុមប្រឹក្សាភិបាល និងតំណាងដើម្បីឱ្យមានផលប្រយោជន៍ស្មើៗគ្នាក្នុងចំណោមអង្គការសមាជិក ដើម្បីឆ្លើយតបទៅនឹងផែនការសកម្មភាពគោលនយោបាយរបស់អង្គការ។ ៦_ធានានូវប្រសិទ្ធិភាពដំណើរការគ្រប់គ្រង បង្កើតនូវគំនិតច្នៃប្រឌិតថ្មីៗសំរាប់ធ្វើការអភិវឌ្ឍដើម្បីឱ្យគ.អ.ស.ក និងអង្គការជាសមាជិកទាំងអស់មានភាពរីកចំរើន។ ត្រូវមានដំណោះស្រាយសមស្របនៅពេលដែលគ.អ.ស.ក ឬអង្គការសមាជិកណាមួយជួបមានបញ្ហា។

បន្ទាប់ពីលទ្ធផលនៃការបោះឆ្នោតត្រូវបានប្រកាស **លោក មាស សំណាង** បានថ្លែងអំណរគុណដល់អង្គការសមាជិកគណៈកម្មាធិការប្រតិបត្តិចាស់ និងបុគ្គលិកនៃអគ្គលេខាធិការជាពិសេស **លោក ជា ពីដែន** ដែលជាប្រធានគណៈកម្មាធិការប្រតិបត្តិចាស់ បានខិតខំប្រឹងប្រែងកំណត់នូវគោលនយោបាយ និងនីតិវិធីច្បាប់នៅក្នុងគ.អ.ស.ក។ ជាងនេះទៀត លោកបានខិតខំប្រឹងប្រែងស្វែងរកមូលនិធិ ភ្ជាប់ទំនាក់ទំនងដ៏ល្អជាមួយម្ចាស់មូលនិធិ ដើម្បីទ្រទ្រង់គ.អ.ស.កឱ្យដំណើរការរហូតមកដល់សព្វថ្ងៃនេះ។ មួយទៀតនោះ លោកបានប្រឹងប្រែងអស់ពីលទ្ធភាពក្នុងការទំនាក់ទំនងល្អបំផុតជាមួយស្ថាប័នរាជរដ្ឋាភិបាល

តទៅទំព័រទី៣

តមកពីទំព័រទី២

ដើម្បីឱ្យគ.អ.ស.ក ដែលជាស្ថាប័នអង្គការក្រៅរដ្ឋាភិបាលលំដាប់ថ្នាក់ជាតិ ទទួលខុសត្រូវក្នុងការសរសេររបាយការណ៍ស្តីពីការអនុវត្តសិទ្ធិកុមារនៃអង្គការសហប្រជាជាតិក្នុងប្រទេសកម្ពុជា។ កិច្ចខិតខំប្រឹងប្រែងទាំងនេះ **លោក មាស សំណាង** គិតថា វាជាគុណប្រយោជន៍ ឧត្តមប្រយោជន៍មួយ និងជាប្រភពធនធានមួយរបស់គ.អ.ស.ក។ **លោក មាស សំណាង** មានប្រសាសន៍ទៀតថា ថ្វីត្បិតតែ **លោក ជា ពីដែន** បានចប់អាណត្តិហើយក្តី ក៏ប៉ុន្តែដោយយោងលើលក្ខន្តិកៈ លោកនឹងត្រូវបានតែងតាំងជាទីប្រឹក្សារបស់គ.អ.ស.ក បន្ទាប់ពីនីតិវិធីជ្រើសរើសទីប្រឹក្សាដែលមានចែងលំអិតក្នុងបទបញ្ជាផ្ទៃក្នុងត្រូវបានអនុម័ត។

**លោក មាស សំណាង** បន្តថា «ខ្ញុំគិតថាក្នុងនាមខ្ញុំបាទជាប្រធានគណៈកម្មាធិការប្រតិបត្តិថ្មីនេះ ខ្ញុំនឹងរៀនសូត្រនូវអ្វីដែលលោកប្រធានគណៈកម្មាធិការចាស់បានខិតខំប្រឹងប្រែងដើម្បីគ.អ.ស.ក ជាពិសេសការស្វែងរកមូលនិធិដើម្បីទ្រទ្រង់ដល់គ.អ.ស.ក ការស្វែងរកមូលនិធិដើម្បីទ្រទ្រង់នូវកម្មវិធីពង្រឹងសមត្ថភាពទាំងបុគ្គលិកគ.អ.ស.ក និងបុគ្គលិកតំណាងមកពីអង្គការសមាជិកដើម្បីពង្រឹងគ.អ.ស.កឱ្យដំណើរការដ៏រឹងមាំដើរឆ្ពោះទៅមុខ ជាពិសេសយើងនឹងរួមគ្នាប្រែក្លាយគ.អ.ស.កឱ្យក្លាយទៅជាមជ្ឈមណ្ឌលឯកសារ ជាពិសេសសំរាប់អ្នកដែលធ្វើការងារពាក់ព័ន្ធនឹងកុមារក្នុងប្រទេសកម្ពុជា»។

ចំណែកឯ **លោកស្រី ថុ ថាវី** អនុប្រធានអង្គការខ្មែរស្ម័គ្រចិត្តដើម្បីអភិវឌ្ឍន៍សហគមន៍ (CVCD) មិនមានវត្តមាននៅថ្ងៃបោះឆ្នោតនោះទេ ប៉ុន្តែលោកស្រីបានជាប់ឆ្នោតជាហេរញ្ញិកនៃគណៈកម្មាធិការប្រតិបត្តិអាណត្តិថ្មីនេះ៕

# ពិធីប្រគល់ប័ណ្ណសរសើរការងារជូនគណៈកម្មាធិការប្រតិបត្តិទើបផុតអាណត្តិ



ពិធីប្រគល់ប័ណ្ណសរសើរការងារជូនដល់សមាជិកគណៈកម្មាធិការប្រតិបត្តិដែលទើបផុតអាណត្តិ ត្រូវបានរៀបចំឡើងដោយគណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ (គ.អ.ស.ក) កាលពីថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៦ នៅអគ្គលេខាធិការដ្ឋាន។ សមាជិកគណៈកម្មាធិការប្រតិបត្តិដែលទើបផុតអាណត្តិរួមមាន៖ **លោក ជា ពីដែន** ជាប្រធាន **លោក មាស សំណាង** ជាអនុប្រធាន **លោក ម៉ិច សុខា** ជាលេខាធិការ **លោក យឹម ប៊ុំ** ជាហេរញ្ញិក និង**លោកស្រី ថុ ថាវី** ជាសមាជិក ព្រមទាំងបានការចូលរួមពីនាយក នាយិកា នាយករងអង្គការជាសមាជិក និងបុគ្គលិក សរុបចំនួន៤២នាក់។

**លោក ជា ពីដែន** ប្រធានអង្គការគាំពារកុមារដែលងាយរងគ្រោះ (VCAO) និងជាអតីតប្រធានគណៈកម្មាធិការប្រតិបត្តិគ.អ.ស.កមានចំណាប់អារម្មណ៍ក្នុងពិធីនោះថា លោកមានសេចក្តីរីករាយណាស់ដែលបានបំរើការងារនៅគ.អ.ស.ក និងសូមថ្លែងអំណរគុណដល់អង្គការសមាជិកដែលបានប្រគល់នូវសេចក្តីទុកចិត្តដោយបានបោះឆ្នោតជ្រើសរើសលោកជាប្រធានគ.អ.ស.កដែលទើបតែផុតអាណត្តិកន្លងទៅនេះ ហើយអង្គការសមាជិកបាននឹងកំពុងខិតខំប្រឹងប្រែងរួមសហការគ្នាក្នុងការអភិវឌ្ឍគ.អ.ស.ក ឱ្យក្លាយទៅជាមជ្ឈមណ្ឌលធនធានមួយដែលមានទាំងធនធានមនុស្ស និងធនធានព័ត៌មានដែលអាចជួយកុមាររងគ្រោះ និងងាយរងគ្រោះនៅក្នុងប្រទេសកម្ពុជា។

**លោក មាស សំណាង** ប្រធានគណៈកម្មាធិការប្រតិបត្តិគ.អ.ស.កអាណត្តិថ្មីមានប្រសាសន៍ក្នុងពិធីនោះដែរថា ការងាររបស់គ.អ.ស.កអាចដំណើរការទៅបានដោយមានការចូលរួមពីអង្គការសមាជិក និងបុគ្គលិកនៃអគ្គលេខាធិការដ្ឋាន។

លោកបន្តថា ក្នុងឆ្នាំ២០០២ដល់ឆ្នាំ២០០៦នេះ មានសមិទ្ធផលជាច្រើនដែលសំរេចបានដោយកិច្ចខិតខំ

តទៅទំព័រទី៤

# របាយការណ៍ស្តីពីការរំលោភបំពានលើកុមារក្នុងត្រីមាសទី៣ឆ្នាំ២០០៦

គណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ (គ.អ.ស.ក) និងអង្គការសមាជិក ពីមួយថ្ងៃទៅមួយថ្ងៃ ក៏ដូចពីមួយត្រីមាសទៅមួយត្រីមាស បានខិតខំយកអស់ពីកំលាំងកាយចិត្តបំពេញភារៈកិច្ច និងបេសកកម្មរបស់ខ្លួនក្នុងការលើកស្ទួយ ផ្សព្វផ្សាយការអនុវត្តសិទ្ធិកុមារ និងការពារកុមារឱ្យចាកផុតពីការរំលោភបំពានគ្រប់រូបភាព។ ទន្ទឹមនឹងនេះ ក្នុងកំឡុងខែកក្កដា ដល់ខែវិច្ឆិកា ឆ្នាំ២០០៦ គ.អ.ស.ក ទទួលបានករណីកុមាររងគ្រោះចំនួន២៤៤ករណី ដែលករណីទាំងនោះប្រមូលពីអង្គការសមាជិក និងសារព័ត៌មានក្នុងស្រុក។ ករណីទាំងនោះរួមមាន÷

១. ការវាយដំលើរាងកាយ មានចំនួន១១ករណីកើនឡើងចំនួន១ករណីប្រៀបធៀបនឹងត្រីមាសទី២។ កុមាររងគ្រោះមានចំនួន១១នាក់ ក្នុងនោះមានកុមារីចំនួន៧នាក់ ដែលអាយុពី១៥ដល់១៧ឆ្នាំមានចំនួន២នាក់ អាយុពី១០ដល់១៤ឆ្នាំមានចំនួន២នាក់ និងអាយុក្រោម៩ឆ្នាំមានចំនួន៣នាក់ រីឯកុមារាមានចំនួន៤នាក់ ដែលអាយុពី១០ដល់១៤ឆ្នាំមានចំនួន៣នាក់ និងអាយុក្រោម៩ឆ្នាំមានចំនួន១នាក់។ ករណីនេះភាគច្រើនកើតនៅទីក្រុងភ្នំពេញ។ រីឯជនល្មើសចំនួន១នាក់រត់គេចខ្លួនបាត់ និងជនល្មើសភាគច្រើនមិនបានបញ្ជាក់។ ជនល្មើសជាឪពុកម្តាយ ជាឪពុកម្តាយចុង។ មូលហេតុមកពីជនល្មើសអវិជ្ជា ក្រីក្រ និងស្រវឹងស្រា។

២. គ្រឿងញៀនមានចំនួន១ករណី មានកុមារាចំនួន១នាក់អាយុ១៥ឆ្នាំ ដែលបានប្រើប្រាស់ និងចែកចាយគ្រឿងញៀន កើតឡើងនៅខេត្តបន្ទាយមានជ័យ។

៣. គ្រោះថ្នាក់ដោយចៃដន្យមានចំនួន១៤ករណីកើនលើសត្រីមាសមុនចំនួន១០ករណី។ កុមារីរងគ្រោះមានចំនួន១១នាក់ អាយុពី១៥ដល់១៧ឆ្នាំចំនួន២នាក់ អាយុពី១០ដល់១៤ឆ្នាំចំនួន៥នាក់ អាយុក្រោម៩ឆ្នាំមានចំនួន៤នាក់ ហើយកុមារាចំនួន៧នាក់ អាយុពី១០ដល់១៤ឆ្នាំចំនួន៣នាក់ អាយុក្រោម៩ឆ្នាំចំនួន៤នាក់។ មូលហេតុមកពី ឡានបុក លង់ទឹក ពស់ចឹក និងឪពុកម្តាយធ្វេសប្រហែសក្នុងការមើលខុសត្រូវកូនរបស់ខ្លួន។

៤. បៀតបៀនកេរ្តិ៍ខ្មាស់មានចំនួន២ករណីថយចុះចំនួន២ករណី។ កុមារីរងគ្រោះមានចំនួន៥នាក់ ១នាក់អាយុពី១០ដល់១៤ឆ្នាំ និង៤នាក់អាយុក្រោម៩ឆ្នាំ។ ករណីនេះកើតឡើងក្នុងខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ។ ជនល្មើសមានចំនួន២នាក់ត្រូវបានឃុំខ្លួនជាបណ្តោះអាសន្ន។ ជនល្មើស១ករណីជាឪពុក និងមួយករណីទៀតមិនបានបញ្ជាក់ មូលហេតុដោយសារនៅជាមួយជនល្មើសតែ២នាក់។

៥. កេងប្រវ័ញ្ចពលកម្មកុមារមានចំនួន១២២ករណីកើនលើសត្រីមាសទី២ចំនួន១១១ករណី។ ករណីនេះកើតឡើងនៅទីក្រុងភ្នំពេញចំនួនមាន១១៨ករណី ខេត្តបន្ទាយមានជ័យ និងព្រៃវែងមានចំនួន១ករណីដូចគ្នា និងក្រៅប្រទេសចំនួន២ករណី។ កុមាររងគ្រោះមានចំនួន១២៨នាក់ ក្នុងនោះកុមារីមានចំនួន១១៧នាក់ ៥៩នាក់អាយុពី១០ដល់១៤ឆ្នាំ ៥៨នាក់អាយុពី១៥ដល់១៧ឆ្នាំ ហើយកុមារាមានចំនួន១១នាក់ ៩នាក់អាយុពី១០ដល់១៤ឆ្នាំ ១នាក់អាយុពី១៥ដល់១៧ឆ្នាំ និង១នាក់អាយុក្រោម៩ឆ្នាំ។ មូលហេតុដោយសារក្រីក្រ កំព្រា គ្រួសារជំពាក់លុយគេ ឪពុកម្តាយបង្ខំទៅធ្វើការ។ កុមាររងគ្រោះភាគច្រើនធ្វើការជាកម្មករសំណង់ បំរើគេតាមផ្ទះ ធ្វើការដោះបំណុល រើសអេតចាយ សុំទាន ជួយកើបថ្ម ខាត់ស្បែកជើងស៊ីឈ្នួលលាងឡានបំរើតាមហាង លើសពីនេះគឺកុមារមិនបានទៅរៀន ព្រមទាំងត្រូវគេវាយធ្វើបាបទៀត។

៦. ឃាតកម្ម អត្តឃាតមានចំនួន២ករណី ថយចុះ១ករណីបើប្រៀបទៅនឹងត្រីមាសទី២ កើតឡើងនៅខេត្តកំពត និងខេត្តព្រះវិហារ។ មានកុមារារងគ្រោះចំនួន១នាក់ និងកុមារីចំនួន១នាក់អាយុក្រោម៩ឆ្នាំ។ ជនល្មើសជាអ្នកជិតខាង និង១នាក់ទៀតមិនបានបញ្ជាក់។ មូលហេតុដោយសារត្រូវគេប្លន់ និងមិនប្រុងប្រយ័ត្ន។ ជនល្មើស១នាក់ត្រូវបានឃុំខ្លួនបណ្តោះអាសន្ន។

៧. សំលាប់ក្រោយពេលរំលោភសេពសន្ថវៈចំនួន២ករណី ថយចុះចំនួន១ករណី។ កុមារីរងគ្រោះមានចំនួន៤នាក់ ១នាក់អាយុក្រោម៩ឆ្នាំ ២នាក់អាយុពី១០ដល់១៤ឆ្នាំ និង១នាក់អាយុពី១៥ដល់១៧ឆ្នាំ ដែលបានកើតឡើងនៅខេត្តកំពង់ស្ពឺ និងខេត្តព្រះវិហារ។ មូលហេតុដោយសារក្មេងស្រីរងគ្រោះដើរម្នាក់ឯង ហើយជនល្មើសជាអ្នកភូមិជាមួយគ្នា។

*តទៅទំព័រទី១១*

តមកពីទំព័រទី១



សិក្ខាមចំនួន៦២នាក់ មកពីសមាជិកគ.អ.ស.ក អង្គការជាតិ-អន្តរជាតិដែលធ្វើការជាមួយកុមារ និងបណ្តាញកុមារអ្នកតស៊ូមតិ។

លោក **ជា ពីដែន** ប្រធានគណៈកម្មាធិការប្រតិបត្តិនៃគណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ (គ.អ.ស.ក)មានប្រសាសន៍ថា រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានធ្វើសច្ចាប័នលើអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារតាំងពីឆ្នាំ១៩៩២។ បន្ទាប់មករាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានផ្ញើរបាយការណ៍ដំបូងរបស់ខ្លួនស្តីពីស្ថានភាពកុមារ ទៅគណៈកម្មាធិការអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារនៅខែធ្នូ ឆ្នាំ១៩៩៧។ រហូតដល់ឆ្នាំ២០០០ គណៈកម្មាធិការអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារបានផ្តល់អនុសាសន៍ចំនួន៣១ចំណុចដល់រាជរដ្ឋាភិបាលកម្ពុជាដើម្បីធ្វើឱ្យស្ថានភាពកុមារក្នុងប្រទេសកាន់តែមានភាពល្អប្រសើរ។

លោកបន្តថា គ.អ.ស.កក៏បានរៀបចំរបាយការណ៍បំពេញបន្ថែមលើកទី១របស់ខ្លួនទៅលើរបាយការណ៍របស់រាជរដ្ឋាភិបាលដើម្បីដាក់ជូនទៅគណៈកម្មាធិការអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារនៅឆ្នាំ១៩៩៩ដែរ ដើម្បីឱ្យអង្គការសហប្រជាជាតិវាយតំលៃពីស្ថានភាពកុមារក្នុងប្រទេសកម្ពុជា។

លោកបន្តទៀតថា នៅក្នុងឆ្នាំ២០០៥ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវផ្ញើរបាយការណ៍លើកទី២របស់ខ្លួនទាក់ទងទៅនឹងការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីកុមារទៅគណៈកម្មាធិការអង្គការសហប្រជាជាតិ។ ប៉ុន្តែមកដល់ឥឡូវរបាយការណ៍លើកទី២របស់រដ្ឋាភិបាលមិនទាន់បានបញ្ចប់នៅឡើយ។ ទន្ទឹមនឹងនេះដែរ គ.អ.ស.កដែលជាសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលថ្នាក់ជាតិធ្វើការយ៉ាងសកម្មទៅលើសិទ្ធិកុមារ ហើយក៏កំពុងរៀបចំសរសេររបាយការណ៍សិក្សាស្តីពីការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារក្នុងប្រទេសកម្ពុជាផងដែរ។ ដើម្បីធ្វើឱ្យសំរេចបាននូវកិច្ចការនេះ គ.អ.ស.កបានសហការជាមួយទីប្រឹក្សាម្នាក់ដើម្បីរៀបចំសរសេររបាយការណ៍នេះ។ ក្រោយពីបានទទួលពង្រាងរបាយការណ៍ គ.អ.ស.ករៀបចំសិក្ខាសាលានៅថ្ងៃនេះដែល មានគោលបំណងឱ្យអ្នកចូលរួមទាំងអស់ រួមទាំងកុមារផងដែរ ដើម្បីផ្តល់អនុសាសន៍ទៅតាមបទពិសោធន៍ និងចំណេះដឹងដែលសិក្ខាកាមទាំងអស់បានជួបប្រទះ និងបានរៀនសូត្រដើម្បីកែសំរួលចំណុចខ្វះចន្លោះនៅក្នុងរបាយការណ៍នេះ ដើម្បីឱ្យរបាយការណ៍មានភាពសុក្រិត និងកាន់តែល្អប្រសើរស្របទៅនឹងស្ថានភាពពិតនៃកុមារនៅក្នុងប្រទេសកម្ពុជា។

លោក **ព្រំ ថាវរី** ទីប្រឹក្សាផ្នែកសិទ្ធិកុមារប្រចាំប្រទេសនៃអង្គការភ្លែនអន្តរជាតិមានប្រសាសន៍ថា លោកបានធ្វើការកត់សំគាល់តូចមួយនៅលើសេចក្តីព្រាងនេះដោយសង្កេតឃើញថា អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកជាច្រើនបាន និងកំពុងធ្វើកិច្ចការជាច្រើនដែលពាក់ព័ន្ធនឹងការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារក្នុងប្រទេសកម្ពុជា ក៏ប៉ុន្តែកិច្ចខិតខំប្រឹងប្រែងរបស់អង្គការក្នុងស្រុកទាំងនោះភាគច្រើនអត់ត្រូវបានលើកយកមកបង្ហាញក្នុងសេចក្តីព្រាងរបាយការណ៍នេះទេ។ ជាយោបល់ផ្ទាល់ខ្លួនរបស់លោក លោកគិតថា គួរតែធ្វើយ៉ាងណាលើកបង្ហាញនូវការប្រឹងប្រែងរបស់អង្គការក្នុងស្រុកទាំងអស់នោះឱ្យបានឃើញអំពីការប្រឹងប្រែងរបស់ខ្លួនក្នុងការចូលរួមជំរុញការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារក្នុងប្រទេសកម្ពុជាក្នុងទិសដៅរួមដើម្បីធ្វើឱ្យសំរេចនូវការអនុវត្តសិទ្ធិកុមារ។

**លោក ភាន់ ភាល់** នាយកកម្មវិធីនៃអង្គការន័រវេស្ស៊ែសង្គ្រោះកុមារមានប្រសាសន៍ថា លោកសង្ឃឹមថារបាយការណ៍ដែលនឹងផ្តល់ជូនរាជរដ្ឋាភិបាលនេះគឺជាព័ត៌មានមួយដែលមានប្រភពច្បាស់លាស់ ដែលអាចជឿជាក់បានត្រឹមត្រូវ និងមានចរិតឯករាជ្យ មិនលំអៀង ដែលទាំងនេះជាសារៈសំខាន់នៅក្នុងរបាយការណ៍។ បើសិនរបាយការណ៍នេះពុំមានចរិតឯករាជ្យ មិនលំអៀងទេនោះ របាយការណ៍នេះនឹងពុំមានន័យអ្វីឡើយ។

លោកបន្តថា រាជរដ្ឋាភិបាលបានបង្ហាញនូវចំនុច

តទៅទំព័រទី៧

# សិក្ខាសាលាស្តីពីការបញ្ជ្រាបចំណេះដឹងផ្នែកសិទ្ធិកុមារដល់មន្ត្រីសុខាភិបាល



សិក្ខាសាលាស្តីពីការបញ្ជ្រាបចំណេះដឹងផ្នែកសិទ្ធិកុមារដល់មន្ត្រីសុខាភិបាលរាជធានីភ្នំពេញ ត្រូវបានរៀបចំដោយគណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ (គ.អ.ស.ក) កាលពីថ្ងៃទី១២_១៤ ខែកញ្ញា ឆ្នាំ២០០៦ នៅអគ្គលេខាធិការដ្ឋានគ.អ.ស.ក។ ក្នុងឱកាសនោះ មានសិក្ខាកាមចំនួន២០នាក់ មកពីទីចាត់ការមន្ទីររាជធានីភ្នំពេញ ស្រុកប្រតិបត្តិកណ្តាល ស្រុកប្រតិបត្តិខាងលិច ស្រុកប្រតិបត្តិខាងត្បូង និងស្រុកប្រតិបត្តិខាងជើង។ សិក្ខាសាលានេះធ្វើឡើងក្នុងគោលបំណង បង្កើនចំណេះដឹង ឬបញ្ជ្រាបចំណេះដឹងអំពីអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារទៅក្នុងផ្នែកថែទាំក្នុងចំណោមអ្នកមានវិជ្ជាជីវៈថែទាំសុខភាពកុមារ សំរាប់អនុវត្តក្នុងការងារប្រចាំថ្ងៃ រឺក៏ដូចជាបង្កើតគោលការណ៍ណែនាំដើម្បីបង្កើនគុណភាពនៃការថែទាំ និងបង្កើតអោយមានបរិយាកាសស្រឡាញ់កុមារ។

**លោក ម៉ិច សុខា** អនុប្រធានគណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ មានប្រសាសន៍នាឱកាសបើកអង្គសិក្ខាសាលាថា គ.អ.ស.កមានកិត្តិយសណាស់ដែលមន្ត្រីសុខាភិបាលបានលះបង់ពេលវេលាមកចូលរួមក្នុងសិក្ខាសាលានេះ ដើម្បីជជែកពិភាក្សា និងចែករំលែកនូវបទពិសោធន៍ការងារប្រចាំថ្ងៃ ក៏ដូចជាមកបញ្ជ្រាបនូវចំណេះដឹងផ្នែកសិទ្ធិកុមារផងដែរ។ លោកសូមសំណូមពរដល់សិក្ខាកាមផ្តល់ការយកចិត្តទុកដាក់ឱ្យកាន់តែខ្លាំងចំពោះកុមារទាំងអស់ផ្តល់ឱកាសអោយពួកគេ និងកុំបោះបង់ពួកគេចោល។

នៅក្នុងឱកាសនៃសិក្ខាសាលានោះ សិក្ខាកាមបានពិភាក្សាកំណត់ផែនការសកម្មភាពដើម្បីដោះស្រាយលើបញ្ហាសុខុមាលភាពកុមារនៅប្រទេសកម្ពុជានាពេលបច្ចុប្បន្ន ដូចជា ១.ត្រូវនិយាយស្តី សុភាពរាបសា ទន់ភ្លន់ជាមួយកុមារ ២.យកចិត្តទុកដាក់ជាពិសេសចំពោះកុមារ ដោយអនុលោមទៅតាមសិទ្ធិកុមារ ៣.គោរពបទដ្ឋានបច្ចេកទេសនៃការពិនិត្យ និងព្យាបាលជម្ងឺ ៤.ត្រូវគោរពក្រមសីលធម៌វិជ្ជាជីវៈ ៥.មានចិត្តអាណិតអាសូរ និងមិនរើសអើងចំពោះកុមារ ៦.មិនត្រូវយកលុយពីកុមារក្រីក្រ ៧.រៀបចំបង្កើតទីធ្លា និងកន្លែងហាត់ប្រាណឱ្យកុមារ ៨.រៀបចំបន្ទប់អ្នកជម្ងឺឱ្យមានអនាម័យ និងបរិយាកាសល្អ ៩.រៀបចំ និងចាត់ឱ្យមានឧបករណ៏ និងសំភារៈគ្រប់គ្រាន់សំរាប់អ្នកជម្ងឺ ១០.ចាត់វិធានការណ៏ឱ្យបុគ្គលិកគោរពម៉ោងពេលធ្វើការ ១១.រៀបចំឱ្យមានផ្ទាំងរូបភាពដែលផ្តល់អត្ថប្រយោជន៍ដល់កុមារបិទក្នុងមន្ទីរពេទ្យ និងនៅតាមមណ្ឌលផ្សេងៗ ១២.កែលំអអគារផ្ទុះធ្លាយ និងបង្កើតឱ្យមានប្រព័ន្ធបង្ហូរទឹក ១៣.ចាត់ឱ្យមានសន្តិសុខយាម ១៤.រៀបចំឱ្យមានកន្លែងទុកដាក់កង់ម៉ូតូ ១៥.រៀបចំកែប្រែបទបញ្ជាផ្ទៃក្នុងមួយចំនួនដោយគិតពីឧត្តមប្រយោជន៍កុមារ ១៦.គួរបន្ថែមបន្ទប់ទឹក និងបង្គន់សំរាប់កុមារ ១៧.ត្រូវផ្តល់អាទិភាពដល់កុមារចូលពិនិត្យជម្ងឺមុន ១៨.បន្ថែមថ្នាំសង្កូវអោយបានគ្រប់គ្រាន់។

ជាចុងក្រោយសិក្ខាកាមសូមសំណូមពរថា ១.សូមបណ្តុះបណ្តាលសិទ្ធិកុមារដល់គ្រប់ស្ថាប័នរដ្ឋទាំងអស់ មិនមែនតែផ្នែកសុខាភិបាលទេ ដើម្បីងាយស្រួលក្នុងការផ្សព្វផ្សាយទូលំទូលាយជាពិសេសគឺផ្នែកអប់រំ។ ២.សូមឱ្យមានផ្ទាំងរូបភាពបិទតាមស្ថាប័ន។ ៣.សូមឱ្យមានវគ្គសិក្ខាសាលាស្តីអំពីសិទ្ធិកុមារលើកក្រោយៗទៀត ដើម្បីយកទៅផ្សព្វផ្សាយបន្ត។ ៤.ចង់មានទស្សនៈកិច្ចសិក្សាដើម្បីធ្វើការអង្កេត និងសិក្សាទៅលើកុមារដទៃទៀត ៥.ចង់ទៅមើលកុមារអនាថាតាមខេត្ត និងក្រៅប្រទេស ៦.សូមឱ្យមានផ្ទាំងរូបភាពបង្ហាញ ពេលមានកម្មវិធីសិក្ខាសាលា។ ៧.សូមឱ្យមានទីធ្លាក្នុងមន្ទីរពេទ្យធំទូលាយ មានកន្លែងកំសាន្តបរិយាកាសល្អ និងព្រមទាំងអនាម័យ។ ៨.សុំផ្ទាំងរូបភាពស្តីអំពីសិទ្ធិកុមារ ដើម្បីយកទៅផ្សព្វផ្សាយនៅពេលដែលរៀនចប់ ៩.សូមឱ្យមានការបង្រៀនរយៈពេល៣ខែម្តង ដើម្បីក្រេបយកមេរៀនអំពីសិទ្ធិកុមារ ១០.សូមឱ្យមានការអប់រំសិទ្ធិកុមារទៅដល់ប្រជាជនតាមជនបទ ១១.សូមឱ្យមានការផ្សព្វផ្សាយនូវសិទ្ធិកុមារដល់ប្រជាជននៅតាមសហគមន៍ ១២.សូមជួយបញ្ជ្រាបឱ្យបានកាន់តែខ្លាំងថែមទៀតអំពីអនុសញ្ញាស្តីពីសិទ្ធិកុមារដល់

តទៅទំព័រទី៧

*តមកពីទំព័រទី៥*

វិជ្ជមានជាច្រើនលើការកែលំអក្នុងកិច្ចការនេះ ជាពិសេសគឺក្រសួងសង្គមកិច្ច ក៏ដូចជាក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារបានបង្ហាញនូវចំនុចវិជ្ជមានជាច្រើនក្នុងការសហការជាមួយអង្គការមិនមែនរដ្ឋាភិបាលក្នុងការអនុវត្ត និងតាមដានការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ។ ដូច្នេះមានន័យថាកិច្ចការនេះគឺឆ្លុះបញ្ចាំងពីការរីកចំរើនអំពីភាពចាស់ទុំ និងតួនាទីរបស់សង្គមស៊ីវិល ពីព្រោះប្រសិនបើសង្គមស៊ីវិលមិនបង្ហាញអំពីភាពចាស់ទុំ មិនមានបទពិសោធន៍ និងពុំមានផលប្រយោជន៍ទេប្រហែលជាពុំអាចទាក់ទាញការយកចិត្តទុកដាក់ពីរាជរដ្ឋាភិបាលបានទេ។ ដូច្នេះ ការដែលរដ្ឋាភិបាលផ្តល់នូវការយកចិត្តទុកដាក់សហការជាមួយអង្គការមិនមែនរដ្ឋាភិបាល គឺជាការឆ្លុះបញ្ចាំងមួយឱ្យឃើញថាសង្គមស៊ីវិលមានតួនាទីមួយមិនអាចខ្វះបានក្នុងការអនុវត្តសិទ្ធិកុមារក្នុងប្រទេសកម្ពុជា។

លោកបន្តទៀតថា វេទិកាពិគ្រោះយោបល់ពេលនេះគឺជាពេលវេលាសំរាប់អង្គការដែលធ្វើការដើម្បីកុមារទាំងអស់ លោកមានការសោកស្តាយដែរដោយឃើញសមាជិករបស់ គ.អ.ស.កមានវត្តមាននៅទីនោះប្រហែលជា៥០%ប៉ុណ្ណោះ។ ដូច្នេះប្រហែលជាតំណាងអង្គការសមាជិកបាន និងកំពុងភ្លេចអំពីតួនាទីរបស់ខ្លួនព្រោះវេទិកានេះជាវេទិកាពិគ្រោះយោបល់ជាពេលវេលាសំរាប់អង្គការសមាជិកទាំងអស់កែលំអលើរបាយការណ៍នេះឱ្យមានលក្ខណៈសុក្រិត ពិសេសគឺត្រូវធ្វើការពិនិត្យ និងពិភាក្សាឡើងវិញលើអនុសាសន៍ព្រោះវាមានសារៈសំខាន់ចាំបាច់ណាស់ ប្រសិនបើអនុសាសន៍នោះមិនមានប្រយោជន៍ និងមិនមានន័យទេ នោះរបាយការណ៍នេះនឹងពុំមានសុពលភាព និងមិនមានតំលៃទេ។ ដូច្នេះយើងត្រូវតែយកបទពិសោធន៍របស់យើងទាំងអស់គ្នា អ្វីដែលយើងមានទាំងអស់គ្នាប្រមូលផ្តុំជជែកគ្នាដើម្បីធ្វើឱ្យអនុសាសន៍ដែលយើងផ្តល់ឱ្យរដ្ឋាភិបាលមានតំលៃដែលគេអាចយកទៅអនុវត្តបាន ហើយក៏ជារបាយការណ៍មួយដែលយើងត្រូវតែសួរគ្នាដែរថា តើអ្វីដែលយើងធ្វើបានល្អហើយ ហើយអ្វីដែលយើងនឹងត្រូវប្រឈមមុខនៅថ្ងៃអនាគត។ របាយការណ៍នេះវាជួយយើងបានច្រើនណាស់ ហើយលោកគិតថា សិក្ខាសាលាថ្ងៃនេះគឺជាឱកាសដ៏ប្រពៃសំរាប់ប្អូនៗកុមារទាំងអស់ សំរាប់អង្គការក្រៅរដ្ឋាភិបាលបានបង្ហាញពីតួនាទីដែលពុំអាចខ្វះបានក្នុងការរួមចំណែកកែលំអប្រែក្លាយលុបបំបាត់ផ្នត់គំនិតអវិជ្ជមានដែលកំពុងមានក្នុងមជ្ឈដ្ឋានជុំវិញកុមារមកលើកុមារ ហើយយើងទាំងអស់គ្នាត្រូវផ្តល់អនុសាសន៍ល្អៗ ដើម្បីឱ្យសង្គមយើងទាំងមូលនេះធ្វើសកម្មភាពជាក់ស្តែងបំរើឱ្យឧត្តមប្រយោជន៍កុមារ។

លោកមានចំណាប់អារម្មណ៍លើរបាយការណ៍នោះដែរថា របាយការណ៍ត្រូវតែជារបាយការណ៍មួយដែលបង្ហាញអំពីស្ថានភាពទូទៅនៅក្នុងកំរិតថ្នាក់ជាតិពុំមែនបង្ហាញអំពីបុគ្គល ឬអង្គភាពណាមួយនោះទេ។ តាមពិតមានកិច្ចការមួយចំនួនធំដែលអង្គការសមាជិកទាំងអស់កំពុងតែធ្វើយ៉ាងសកម្ម និងយ៉ាងផុលផុស។ ដូច្នេះត្រូវតែពិចារណាទាំងអស់គ្នាថាតើ របាយការណ៍នេះវាគួរតែជារបាយការណ៍មួយក្នុងទំរង់ថ្នាក់ជាតិដែលឆ្លុះបញ្ចាំងពីការរីកចំរើនទូទៅ និងបញ្ហាដែលកំពុងប្រឈមទាំងអស់គ្នា៕

---

*តមកពីទំព័រទី៦*

មន្ត្រីសុខាភិបាលគ្រប់ជាន់ថ្នាក់។ ១៣.សូមឱ្យមន្ទីរពេទ្យ មណ្ឌលសុខភាពមានទីកន្លែងសំរាប់កុមារ មុនពេលចូលជួបគ្រូពេទ្យ និងសូមឱ្យមានបន្ទប់ទឹកសំរាប់អ្នកជម្ងឺ។

ចុងបញ្ចប់នេះ មុននឹងអង្គសិក្ខាសាលាត្រូវបានបិទ **លោក ម៉ិច សុខា** បានថ្លែងផ្តាំផ្ញើដល់សិក្ខាកាមទាំងអស់ថា សូមឱ្យមន្ត្រីសុខាភិបាលយកចំណេះដឹងស្តីពីសិទ្ធិកុមារដែលបានចូលរួមក្នុងថ្ងៃនោះ ទៅអនុវត្តនៅក្នុងគ្រួសារ និងសហគមន៍ ជាពិសេសនៅក្នុងមន្ទីរពេទ្យតែម្តង។ លោកសូមថ្លែងអំណរគុណចំពោះសិក្ខាកាមដែលបានចំណាយពេលវេលាមកចូលរួមក្នុងវគ្គសិក្ខាសាលានោះ ហើយសូមថ្លែងអំណរគុណចំពោះ **លោក ស៊ឹម តារា លោក សុន ពេញ** និង **លោក អ៊ុំ គឹមអ៊ុន** ដែលជាតំណាងមកពីអង្គការសមាជិក ចូលរួមជួយសំរបសំរួលក្នុងសិក្ខាសាលានោះ៕

---

*តមកពីទំព័រទី១១*

ដើម្បីសិទ្ធិកុមារ (គ.អ.ស.ក)សូមអំពាវនាវជូនចំពោះរាជរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាលជាតិ-អន្តរជាតិ សង្គមស៊ីវិលនានា ក្រុមគ្រួសារ សាធារណៈជន រួមគ្នាទប់ស្កាត់ លុបបំបាត់រាល់សកម្មភាពរំលោភបំពានលើកុមារ និងបំផ្លាញឧត្តមប្រយោជន៍របស់កុមារទាំងអស់គ្នា។ មិនតែប៉ុណ្ណោះ សូមជួយលើកស្ទួយការអនុវត្តសិទ្ធិកុមារ និងការអភិវឌ្ឍកុមារក្នុងពេលអនាគតអោយកាន់ភ្លឺត្រចះត្រចង់៕

*តមកពីទំព័រទី៣*

ប្រឹងប្រែងពីសមាជិកគណៈកម្មាធិការប្រតិបត្តិ អង្គការសមាជិក និងបុគ្គលិកអគ្គលេខាធិការដ្ឋាន ដែលការងារទាំងអស់នោះពិតជាបានផ្តល់នូវឧត្តមប្រយោជន៍ដល់កុមារ។ លោកសង្ឃឹមថា ទៅថ្ងៃអនាគត ជាពិសេសផែនការយុទ្ធសាស្រ្ត២០០៦-២០០៩ របស់គ.អ.ស.ក ដែលបានដាក់ជូនម្ចាស់មូលនិធិ អង្គការសមាជិក និងបុគ្គលិកគ.អ.ស.កទាំងអស់ នឹងរួមកំលាំងគ្នាដើម្បីអនុវត្តនូវផែនការយុទ្ធសាស្រ្តនេះបន្តទៀត។ លោកមានប្រសាសន៍ទៀតថា ក្នុងនាមគណៈកម្មាធិការប្រតិបត្តិថ្មី លោកនឹងប្រឹងប្រែងអនុវត្តអ្វីដែលបានកំណត់បន្តពីគណៈកម្មាធិការប្រតិបត្តិចាស់ និងអង្គការសមាជិកដែលបានចូលរួម។ លោកនឹងអនុវត្តបន្តដោយរួមសហការជាមួយអង្គការក្រៅរដ្ឋាភិបាលជាតិ-អន្តរជាតិ-សហប្រជាជាតិ និងស្ថាប័នរាជរដ្ឋាភិបាលដោយប្រឹងប្រែងឱ្យទទួលបាននូវជោគជ័យ។ ដើម្បីអនុវត្តការងារនេះបាន គណៈកម្មាធិការប្រតិបត្តិអាណត្តិថ្មីនឹងពិនិត្យកែលំអរនូវគោលនយោបាយ និងនីតិវិធីមួយចំនួនដើម្បីធ្វើឱ្យមានភាពប្រសើរឡើង ដែលថ្មីៗនេះដោយកិច្ចខិតខំប្រឹងប្រែងរបស់គណៈកម្មាធិការប្រតិបត្តិអាណត្តិចាស់ បានអនុម័តនូវលក្ខន្តិកៈចប់រួចរាល់ហើយ ប៉ុន្តែនៅមិនទាន់ធ្វើវិសោធនកម្មដើម្បីកែប្រែលើបទបញ្ជាផ្ទៃក្នុង និងនីតិវិធីមួយចំនួនទៀត។ ជាពិសេសទៀត ក្នុងនាមគណៈកម្មាធិការប្រតិបត្តិថ្មី លោកនឹងរួមសហការជាមួយអង្គការសមាជិកនឹងប្រែក្លាយ គ.អ.ស.កឱ្យទៅជាមជ្ឈមណ្ឌលឯកសារ និងព័ត៌មានសំរាប់ជួយកុមារ ឬសំរាប់អ្នកដែលចង់សិក្សាស្រាវជ្រាវព័ត៌មានផ្សេងៗដែលពាក់ព័ន្ធនឹងកុមារ។

ជាចុងក្រោយលោកបញ្ជាក់ថា នៅមានការងារមួយទៀតដើម្បីធ្វើឱ្យសំរេចការងារទាំងអស់នេះបាន គឺគណៈកម្មាធិការប្រតិបត្តថ្មីនឹងពិភាក្សាដើម្បីស្វែងរកមូលនិធិក្នុងការកសាងសមត្ថភាពដល់បុគ្គលិកដែលបំរើការងារនៅអគ្គលេខាធិការដ្ឋានផង ក៏ដូចជាអង្គការសមាជិករបស់គ.អ.ស.កផងដែរ។ ដូច្នេះកិច្ចខិតខំប្រឹងប្រែងទាំងអស់នេះលោកគិតថា មិនមែនមានតែគណៈកម្មាធិការប្រតិបត្តិទាំង៥រូបអាចអនុវត្តការងារនេះបានទេ លោកថាសមិទ្ធផលទាំងអស់នោះ គឺកើតមានឡើងដោយមានការចូលរួមពីអង្គការសមាជិកផង។ លោកសូមថ្លែងអំណរគុណចំពោះការចូលរួមសហការរបស់អង្គការសមាជិក បុគ្គលិក គ.អ.ស.ក និងជាពិសេសម្ចាស់មូលនិធិអង្គការសេវ់ស្រ្ស៊េសង្គ្រោះកុមារ និងម្ចាស់មូលនិធិមួយចំនួនទៀតដែលបានឧបត្ថម្ភដល់គ.អ.ស.ក។

**លោក ស៊ុំ ចំរុង** អគ្គលេខាធិការនៃគ.អ.ស.កបានរាយការណ៍អំពីសមិទ្ធផលសំខាន់ៗក្នុងកំឡុងឆ្នាំ២០០២ ដល់២០០៦ ក្រោមកិច្ចដឹកនាំ និងសហការយ៉ាងជិតស្និត រវាងគណៈកម្មាធិការប្រតិបត្តិអាណត្តិចាស់ អង្គការសមាជិក និងបុគ្គលិកអគ្គលេខាធិការដ្ឋាន។ សមិទ្ធផលមួយចំនួនធំបានលេចចេញជារូបរាងឡើងរួមមានៈ

១.ការអភិវឌ្ឍអង្គភាព

-គណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ ត្រូវបានចុះបញ្ជីទទួលស្គាល់ជាផ្លូវការដោយក្រសួងមហាផ្ទៃនៅខែសីហា ឆ្នាំ២០០២។

- លក្ខន្តិកៈត្រូវបានវិសោធនកម្ម សំដៅពង្រឹងប្រសិទ្ធិភាព តម្លាភាព និងការទទួលខុសត្រូវក្នុងគ.អ.ស.ក។

- បទបញ្ជាផ្ទៃក្នុងត្រូវបានបង្កើតឡើង។

- សេចក្តីព្រាងបទបញ្ជាផ្ទៃក្នុងថ្មី សេចក្តីព្រាងនីតិវិធីរដ្ឋបាល សេចក្តីព្រាងនីតិវិធីគ្រប់គ្រង និងចាត់ចែងថវិកាត្រូវបានរៀបចំរួចរាល់រង់ចាំការអនុម័តសំរេចដោយគណៈកម្មាធិការប្រតិបត្តិអាណត្តិថ្មី។

២.ការអភិវឌ្ឍផ្នែកកម្មវិធីមួយចំនួនត្រូវបានបង្កើតឡើងថ្មីៗសំដៅលើកកំពស់ការយល់ដឹងអំពីសិទ្ធិកុមារ ការតស៊ូមតិ និងតាមដានការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារក្នុងប្រទេសកម្ពុជាដូចជាៈ

- ផែនការយុទ្ធសាស្រ្តឆ្នាំ២០០៦-២០០៩ត្រូវបានបង្កើត។

- កម្មវិធីផ្នែកព័ត៌មានត្រូវបានបង្កើតដើម្បីប្រមូលចងក្រង និងវិភាគព័ត៌មានស្តីពីស្ថានភាពកុមារនៅកម្ពុជា ជាពិសេស ការតាមដានការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិ

*តទៅទំព័រទី៩*

តមកពីទំព័រទី៨

ស្តីពីសិទ្ធិកុមារ។

- ក្រុមការងារចំនួន៥ ក្នុងចំណោមសមាជិកត្រូវបានបង្កើតក្នុងទិសដៅជួយដល់អគ្គលេខាធិការដ្ឋានក្នុងការប្រមូលចងក្រង និងវិភាគទិន្នន័យស្តីពីស្ថានភាពរបស់កុមារ និងរៀបចំរបាយការណ៍ទៅអង្គការសហប្រជាជាតិ។

- របាយការណ៍ស្តីពីការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារនៅកម្ពុជា ឆ្នាំ២០០០-២០០៥ កំពុងដំណើរការសិក្សា និងវិភាគ ហើយនឹងត្រូវបញ្ចប់ក្នុងពេលឆាប់ៗនេះ។

- កម្មវិធីផ្តល់ប្រឹក្សាដល់កុមារត្រូវបានបង្កើតដោយផ្តោតទៅលើកុមារងាយរងគ្រោះ និងរងគ្រោះ។

- បណ្ណាល័យត្រូវបានកែលំអដើម្បីផ្តល់ឱកាសអោយកុមារ អង្គការសមាជិក និងសាធារណៈជន ចូលអានសៀវភៅ និងឯកសារនានាដែលទាក់ទងនឹងកុមារ។

- បណ្តាញកុមារអ្នកតស៊ូមតិ ត្រូវបានបង្កើតដោយមានការសម្របសម្រួលពីគ.អ.ស.ក ដើម្បីលើកកំពស់ការចូលរួមរបស់កុមារ ព្រមទាំងផ្តល់ឱកាសឱ្យពួកគេបានចូលរួមសកម្មភាពផ្សេងៗ ដូចជាសន្និសិទពិភពលោកប្រឆាំងពលកម្មកុមារនៅប្រទេសអ៊ីតាលី និងប្រទេសឥណ្ឌា។

-សមាជិកបណ្តាញកុមារអ្នកតស៊ូមតិត្រូវបានបង្កើនសមត្ថភាពទាក់ទងនឹងការងារតស៊ូមតិ ហើយពួកគេបានចូលរួមផ្តល់យោបល់លើសេចក្តីព្រាងរបាយការណ៍ស្តីពីការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារនៅកម្ពុជាដែលរៀបចំដោយគណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ។

- កម្មវិធីផ្នែកសិទ្ធិកុមារត្រូវបានបង្កើត ដើម្បីផ្សព្វផ្សាយសិទ្ធិកុមារដល់មន្ត្រីសុខាភិបាល និងអ្នកដែលធ្វើការពាក់ព័ន្ធនឹងកុមារ។

-សកម្មភាពតស៊ូមតិ និងលើកកំពស់ការយល់ដឹងក្នុងចំណោមមន្ត្រីរដ្ឋាភិបាល និងសាធារណៈជន អំពីបញ្ហាសិទ្ធិកុមារត្រូវបានបង្កើតតាមរយៈសិក្ខាសាលា យុទ្ធនាការ១មិថុនា ខ្សែវីដេអូខ្លី ខិត្តប័ណ្ណ ព្រឹត្តិបត្រ ប្រតិទិន និងសេចក្តីថ្លែងការណ៍អំពីបញ្ហាសិទ្ធិកុមារ...។ល។

៣. ការបង្កើនសមត្ថភាពអង្គការជាសមាជិក

- បានប្រមូលធនធានទាំងក្នុង និងក្រៅប្រទេស ដើម្បីបណ្តុះបណ្តាលជំនាញដល់បុគ្គលិកអគ្គលេខាធិការដ្ឋាន និងបុគ្គលិករបស់អង្គការជាសមាជិក ដូចជា សិទ្ធិកុមារ ការងារតស៊ូមតិ ការបញ្ជ្រាបការចូលរួមរបស់កុមារ អំពើហិង្សាលើកុមារ ការរៀបចំផែនការយុទ្ធសាស្ត្រ ភាពជាអ្នកដឹកនាំខ្លួនឯង។ ចិត្តវិទ្យាលូតលាស់របស់កុមារ ការរៀបចំបង្កើតកំរងសំនួរ ព្រមទាំងការចែករំលែកចំណេះដឹងផ្សេងៗក្នុងចំណោមអង្គការសមាជិក និងធនធានមនុស្សពីស្ថាប័នធំៗនានានៅក្នុងប្រទេស...។ល។

៤. ការងារទំនាក់ទំនងធ្វើការសហការយ៉ាងរលូនក្នុងចំណោមអង្គការជាសមាជិកទាំងអស់របស់គណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារតាមរយៈការជួយជ្រោមជ្រែងគ្នាទៅវិញទៅមក ក្នុងស្មារតីសាមគ្គីភាព និងទទួលខុសត្រូវ បានធ្វើកិច្ចសហការយ៉ាងជិតស្និតជាមួយស្ថាប័ននានារបស់រាជរដ្ឋាភិបាល ជាពិសេសក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ក្នុងការងារតស៊ូមតិ ការរៀបចំសេចក្តីព្រាងគោលនយោបាយ និងផែនការជាតិនានាទាក់ទងនឹងកុមារ ជាពិសេសការចូលរួមក្នុងការផ្តល់យោបល់ និងអនុសាសន៍លើការរៀបចំសេចក្តីព្រាងរបាយការណ៍របស់រដ្ឋាភិបាលស្តីពីការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារនៅកម្ពុជា។ បានធ្វើទំនាក់ទំនងរួមសហការយ៉ាងល្អជាមួយអង្គការជាដៃគូរផ្សេងៗដូចជា វេទិកាអង្គការមិនមែនរដ្ឋាភិបាល បណ្តាញពលកម្មកុមារនៅអាស៊ីអ៊ិកផាតកម្ពុជា កូសេកាំ...។ល។ ដើម្បីចូលរួមចំណែកធ្វើការកែលំអរស្ថានភាពរបស់កុមារនៅកម្ពុជា បានធ្វើកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និតជាមួយភាគីម្ចាស់ជំនួយក្នុងទិសដៅអនុវត្តគំរោងការងារ ជាពិសេសជាមួយអង្គការន័រវេស្ស៊ីសង្គ្រោះកុមារ សំដៅអនុវត្តការងារក្នុងភាពជាដៃគូរប្រកបដោយប្រសិទ្ធិភាព តម្លាភាព និងការទទួលខុសត្រូវខ្ពស់។ កិច្ចព្រមព្រៀងបន្តផ្តល់ជំនួយរយៈពេល៤ឆ្នាំចាប់ពីឆ្នាំ២០០៦-២០០៩ ត្រូវបាន

តទៅទំព័រទី១០

តមកពីទំព័រទី៩

រៀបចំឡើង រវាងគណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ និងអង្គការន័រវេស៊្យសង្គ្រោះកុមារ ក្នុងទិសដៅលើកកំពស់អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារនៅកម្ពុជា។ ក្រៅពីនេះមានភាគីម្ចាស់ជំនួយផ្សេងៗទៀតដែលរួមចំណែកជួយឧបត្ថម្ភផ្នែកបច្ចេកទេស និងថវិកាដល់គណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ ដូចជា អង្គការភ្លែនអន្តរជាតិកម្ពុជា អង្គការស្ពានដើម្បីសន្តិភាព អង្គការស៊ីដសេ អង្គការសហការ អង្គការទស្សនៈពិភពលោក អង្គការ Church World Service អង្គការកាតូលិកសង្គ្រោះកុមារ អង្គការUnited World College នៅសាំងហ្គាពួរ និងអង្គការពលកម្មកុមារនៅអាស៊ី...។ល។

បន្ទាប់ពីកម្មវិធីត្រូវបានបញ្ចប់ គ.អ.ស.កក៏មានពិធីជប់លៀងធ្វើឡើងសំរាប់អបអរចំពោះគណៈកម្មាធិការប្រតិបត្តិថ្មីដែលទើបតែជាប់ឆ្នោត និងសំរាប់អរគុណចំពោះគណៈកម្មាធិការប្រតិបត្តិចាស់ទើបតែចប់អាណត្តិ ដែលបានចំណាយកំលាំងចិត្តកំលាំងកាយ ប្រាជ្ញាស្មារតី និងពេលវេលាធ្វើអោយគណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ មានដំណើរការឈានទៅមុខកាន់តែប្រសើរក្នុងមួយឆ្នាំទៅមួយឆ្នាំ ព្រមទាំងមានការចូលរួមជាភ្ញៀវកិត្តិយសពីសំណាក់នាយក នាយិកា និងបុគ្គលិកអង្គការសមាជិកយ៉ាងកុះករ។ កម្មវិធីនេះទទួលការឧបត្ថម្ភដោយៈ

| | |
|---|---|
| _លោក **មាស សំណាង** | ថវិកាចំនួន ៥០$ |
| _លោក **ព្រុំ ធី** | ថវិកាចំនួន ៣០$ |
| _លោក **ស៊ុំ ចំរុង** | ថវិកាចំនួន ៥០$ |
| _លោកស្រី **ថូ ថវរី** | ថវិកាចំនួន ៣០$ |
| _កញ្ញា **លី សុទ្ធារី** | ថវិកាចំនួន២០០,០០០៛ |
| _លោក **ម៉ិច សុខា** | ឧបករណ៍ និងក្រុមតន្ត្រី |
| _បុគ្គលិកគ.អ.ស.ក | ថវិកាចំនួន ៤០$ |

តមកពីទំព័រទី១

(គ.អ.ស.ក) រយៈពេល៥ថ្ងៃ ពីថ្ងៃទី១៧_២១ ខែកក្កដា ឆ្នាំ២០០៦ នៅអគ្គលេខាធិការដ្ឋានគ.អ.ស.ក។ សិក្ខាសាលានេះមានសិក្ខាកាមចូលរួមចំនួន៤២រូប ជាតំណាងមកពីអង្គការសមាជិករបស់គ.អ.ស.ក។ សិក្ខាសាលានេះធ្វើឡើងក្នុងគោលបំណងដើម្បីឱ្យក្រុមការងារទាំង៥របស់គ.អ.ស.កចេះបង្កើតនូវកំរងសំនួរ របៀបសំភាសន៍ និងការសរសេររបាយការណ៍ស្តីពីការអនុវត្តសិទ្ធិកុមារ។

**លោក ជា ពិដែន** មានប្រសាសន៍ថា សិក្ខាសាលានេះមានសារៈសំខាន់ណាស់សំរាប់អង្គការសមាជិក ក៏ដូចគ.អ.ស.កដែរ ព្រោះគ.អ.ស.កបានបង្កើតក្រុមការងារទាំង៥សំរាប់សរសេររបាយការណ៍ស្តីពីការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារក្នុងប្រទេសកម្ពុជា ដូច្នេះសមាជិកក្នុងក្រុមនីមួយៗចាំបាច់ត្រូវតែចេះបង្កើតកំរងសំនួរ និងសរសេររបាយការណ៍។

បន្ទាប់ពីសិក្សាបាន៣ថ្ងៃមក សិក្ខាកាមបានយល់ដឹងពីរបៀបធ្វើកំរងសំនួរ និងការសង្កេត ហើយសិក្ខាកាមបានចែកជាក្រុម និងជ្រើសរើសប្រធានបទដើម្បីចុះទៅសិក្សា អង្កេតនៅគំនរសំរាមស្ទឹងមានជ័យ។ សិក្ខាកាមទាំងអស់បានចុះទៅសង្កេត និងសំភាសន៍កុមារ និងប្រជាជនដែលរស់នៅតំបន់គំនរសំរាមស្ទឹងមានជ័យទៅតាមកំរងសំនួរ។ សកម្មភាពយ៉ាងសកម្មរបស់សិក្ខាកាមបានធ្វើអោយមានការចាប់អារម្មណ៍ពីប្រជាជននៅទីនោះមួយចំនួនធំ ហើយប្រជាជនខ្លះមិនបានឆ្លើយឡេះក្បាយទេព្រោះពួកគេរវល់តែរើសអេតចាយនៅពេលដែលរថយន្តសំរាមមកដល់។ សកម្មភាពដែលយើងសង្កេតបាននោះ គឺប្រជាជនក៏ដូចជាកុមារតូចៗ បានរស់នៅលើគំនរសំរាម ហូបចំណីអាហារនៅទីនោះពោរពេញទៅដោយរុយរោម និងក្លិនស្អុយឆ្អាប ហើយមានកុមារខ្លះទៀតមានតំបៅលើរាងកាយដោយពួកគេមុតកម្ទេចកម្ទីអំបែងដប ដែក និងវត្ថុរឹងផ្សេងៗ។ ក្នុងពេលនោះមានប្រជាជន និងកុមារតូចៗ បានសំណូមពរដល់រាជរដ្ឋាភិបាល អង្គការជាតិ-អន្តរជាតិ សង្គមស៊ីវិល និងសប្បុរជនមេត្តាជួយដល់ពួកគេឱ្យមានជីវភាពសមរម្យ បានទៅរៀនសូត្រ និងសំអាតកន្លែងសំរាមអោយមានសណ្តាប់ធ្នាប់ល្អ។ ជាចុងបញ្ចប់ សិក្ខាកាមស្នើរសុំឱ្យគ.អ.ស.កមានបើកវគ្គវិភាគទិន្នន័យក្នុងកំព្យូទ័របន្ថែមទៀត៕

*តមកពីទំព័រទី៤*

ជនល្មើសទាំង២នាក់ត្រូវឃុំខ្លួនជាបណ្តោះអាសន្ន។

៨. កុមារកំព្រាឪពុកម្តាយស្លាប់ដោយជំងឺអេដស៍មានចំនួន៤ករណី កើនចំនួន២ករណី កុមារទាំងនោះមានស្រុកកំណើតនៅខេត្តកណ្តាល និងទីក្រុងភ្នំពេញ។ កុមារីរងគ្រោះមានចំនួន២នាក់អាយុពី១០ដល់១៤ឆ្នាំ ហើយកុមារាចំនួន៣នាក់ ១នាក់អាយុពី១៥ដល់១៧ឆ្នាំ ១នាក់អាយុពី១០ដល់១៤ឆ្នាំ និង១នាក់ក្រោមអាយុ៩ឆ្នាំ។

៩. អំពើអនាចារមានចំនួន២ករណីកើនចំនួន១ករណី ដែលកើតឡើងនៅទីក្រុងភ្នំពេញ។ មានកុមារីរងគ្រោះ២នាក់ ១នាក់អាយុ១៣ឆ្នាំ និង១នាក់ទៀតអាយុ១៤ឆ្នាំ។ ជនល្មើសមាន២នាក់ ១នាក់អាយុពី៦០ដល់៦៦ឆ្នាំ និង១នាក់ទៀតអាយុពី៦៧ដល់៧៣ឆ្នាំ ហើយជនល្មើសត្រូវជាប់ឃុំជាបណ្តោះអាសន្នរងចាំសវនាការ។

១០. រំលោភសេពសន្ថវៈចំនួន៤៧ករណីថយចុះ២ករណីបើធៀបទៅត្រីមាសទី២។ មានកុមារីរងគ្រោះចំនួន៥២នាក់ អាយុពី១៥ដល់១៧ឆ្នាំចំនួន១៨នាក់ អាយុពី១០ដល់១៤ឆ្នាំចំនួន២១នាក់ និងអាយុក្រោម៩ឆ្នាំចំនួន១៣នាក់។ ករណីទាំងនេះកើតឡើងនៅខេត្តបន្ទាយមានជ័យចំនួន៦ករណី ខេត្តបាត់ដំបងចំនួន៤ករណី ខេត្តកំពង់ចាមចំនួន១ករណី ខេត្តកំពង់ឆ្នាំងចំនួន៤ករណី ខេត្តកំពង់ស្ពឺចំនួន២ករណី ខេត្តកំពង់ធំចំនួន៣ករណី ខេត្តកំពតចំនួន១ករណី ខេត្តកណ្តាលចំនួន៦ករណី ខេត្តក្រចេះចំនួន១ករណី ខេត្តឧត្តរមានជ័យចំនួន១ករណី ខេត្តព្រះវិហារចំនួន១ករណី ខេត្តសៀមរាបចំនួន៣ករណី ខេត្តស្វាយរៀងចំនួន១ករណី ខេត្តតាកែវចំនួន២ករណី ក្រុងប៉ៃលិនចំនួន១ករណី ក្រុងព្រះសីហនុចំនួន២ករណី និងទីក្រុងភ្នំពេញចំនួន៩ករណី។ មូលហេតុដែលកុមារីរងគ្រោះត្រូវបានរំលោភសេពសន្ថវៈដោយសារចាញ់បោកសង្សា លួងលោមរួមភេទ ទៅឃ្វាលគោម្នាក់ឯង ជនល្មើសប្រើល្បិចលួងលោមឱ្យលុយ ដេកផ្ទះជនល្មើស នៅពីរនាក់ជនល្មើស នៅផ្ទះជនល្មើស ម្តាយមិននៅផ្ទះ ទៅព្រៃជាមួយជនល្មើស ទៅបត់ជើងពេលយប់ម្នាក់ឯង ទៅបាចត្រីជាមួយជនល្មើស ទៅមើលទូរទស្សន៍នៅផ្ទះជនល្មើស លួងលោមនាំដើរលេង ជនល្មើសបង្អកស្រាឱ្យស្រវឹង ទៅចាប់ក្តាមម្នាក់ឯង ដើរម្នាក់ឯង...។ល។ ជនល្មើសមានចំនួន៤៧នាក់ ៤នាក់អាយុពី១៥ដល់១៧ឆ្នាំ ១៦នាក់អាយុពី១៨ដល់២៤ឆ្នាំ ៥នាក់អាយុពី២៥ដល់៣១ឆ្នាំ ៨នាក់អាយុពី៣២ដល់៣៨ឆ្នាំ ៤នាក់អាយុពី៣៩ដល់៤៥ឆ្នាំ ១នាក់អាយុពី៤៦ដល់៥២ឆ្នាំ ១នាក់អាយុពី៥៣ដល់៥៩ឆ្នាំ ២នាក់អាយុពី៦០ដល់៦៦ឆ្នាំ និង៦នាក់មិនបានបញ្ជាក់ ហើយជនល្មើសភាគច្រើនជាអ្នកជិតខាង អ្នកភូមិ អ្នកស្គាល់គ្នា ឪពុកមា ឪពុកចុង ឪពុកបង្កើត សង្សារ ខ្លះទៀតមិនបានបញ្ជាក់។ ជនល្មើសចំនួន៣៤នាក់ត្រូវបានឃុំខ្លួនបណ្តោះអាសន្ន ១នាក់នៅក្រៅឃុំ ៣នាក់រត់បាត់ ១នាក់ប្រជាជនវាយស្លាប់ និង៨នាក់មិនបានបញ្ជាក់។ ជនល្មើសសារភាពចំពោះមុខសមត្ថកិច្ចថា មកពីគេមើលរឿងសិច ខ្លះទៀតថាស្រវឹងស្រាទើបនាំឱ្យចង់ប្រព្រឹត្តរឿងនេះ។

១១. ករណីជួញដូរកុមារមានចំនួន៧ករណីកើនឡើងចំនួន៣ករណី កើតឡើងនៅខេត្តកណ្តាលមានចំនួន១ករណី ក្រុងប៉ៃលិនមានចំនួន១ករណី ក្រុងព្រះសីហនុមានចំនួន១ករណី ខេត្តព្រៃវែងមានចំនួន១ករណី និងទីក្រុងភ្នំពេញចំនួន៣ករណី។ កុមារីរងគ្រោះមានចំនួន៧នាក់ ១នាក់អាយុក្រោម៩ឆ្នាំ និង៦នាក់អាយុពី១៥ដល់១៧ឆ្នាំ។មូលហេតុដោយសារឪពុកម្តាយជំពាក់លុយគេ គេបបួលទៅលក់កាហ្វេជនល្មើសប្រើល្បិចហៅទៅធ្វើការ និងចាញ់បោកគេ។ ជនល្មើសមានចំនួន៣នាក់ ១នាក់អាយុពី១០ដល់១៤ឆ្នាំ ១នាក់អាយុពី១៨ដល់២៤ឆ្នាំ និង១នាក់អាយុពី៣២ដល់៣៨ឆ្នាំ ជនល្មើសទាំង៣នាក់ត្រូវបានឃុំខ្លួនជាបណ្តោះអាសន្ន។

១២. កុមារងាយរងគ្រោះមានចំនួន១៧ករណីថយចុះចំនួន៥ករណី។ កុមារីត្រូវបានជួយសង្គ្រោះចំនួន១៧នាក់ ក្នុងនោះ១៣នាក់អាយុពី១៥ដល់១៧ឆ្នាំ ៣នាក់អាយុពី១០ដល់១៤ឆ្នាំ និង១នាក់អាយុក្រោម៩ឆ្នាំ។ ខេត្តដែលមានអត្រាកើនឡើងខ្លាំងចំនួន៥ករណីនៅក្រុងព្រះសីហនុ និងចំនួន៥ករណីនៅខេត្តតាកែវ។ មូលហេតុដោយសារ ក្រីក្រ កំព្រា គ្មានទីពឹង សេពគបមិត្តមិនចូលរៀន។

យោងតាមករណីរំលោភបំពានលើកុមារក្នុងត្រីមាសទី៣ចំនួន២៤៤ករណីបានកើនជិតទ្វេដង បើប្រៀបទៅនឹងត្រីមាសទី២មានចំនួនតែ១២៩ករណី ហើយករណីទាំងនេះនឹងកើនឡើងទៀត ព្រោះអង្គការសមាជិកខ្លះមិនទាន់បានផ្តល់ឱ្យ ដែលធ្វើអោយគ. អ. ស. ក និងអង្គការសមាជិកគ. អ. ស. កមានការព្រួយបារម្ភណ៍ជាខ្លាំងទៅលើការអនុវត្តសិទ្ធិកុមារនៅក្នុងប្រទេសកម្ពុជា។ ដូច្នេះក្នុងនាមគណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាល

*តទៅទំព័រទី៧*

## កំណាព្យ កុមារយ៉ាប់យ៉ឺន

បទពាក្យ៧

កុមារយ៉ាប់យ៉ឺនគួរឱ្យអាណិត
គ្មានសំលៀកបំពាក់ចិត្តតោកយ៉ាក
ផ្ទះក៏ផ្លុះធ្លាយគ្មានជញ្ជាំង
គ្មានភាពកក់ក្តៅពីអ្វីមួយ
កុមារយ៉ាប់យ៉ឺននឹងក្លាយជា
ហេតុអ្វីបន្សល់ទុករឿងហ្នឹង
យើងត្រូវចេះជួយកុមារយ៉ាប់យ៉ឺន
យើងត្រូវតែមានចិត្តសាមណេរ

ផ្នែកខាងផ្លូវចិត្តក៏ពិបាក
គួរឱ្យពិបាកចិត្តជំនួស។
ឬក៏គ្មានរនាំងសំរាប់ជួយ
មានតែទុកព្រួយក្នុងគ្រួសារ។
ជនដែលវេទនាគ្មានទីពឹង
ឱ្យគេទៅពឹងលើអ្នកណា។
មិនអាចភ្លើតភ្លើននឹងគេទេ
មិនអាចភ្លេចទេជួយគេផង៕

និពន្ធដោយ កុមារា ស៊ុន វីណា និងកុមារី រ៉ឹង បញ្ញា រៀនថ្នាក់ទី៥គ នៃសាលាសឿ ភូមិសឿ ឃុំសឿ ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ



គូរដោយ កុមារា សូ ពន្លី អាយុ១៣ឆ្នាំ មកពីអង្គការគ្រួសារថ្មី ទទួលចំណាត់ថ្នាក់លេខ១ នៃការប្រលងគំនូរក្រុមកុមារអាយុពី១៣_១៥ឆ្នាំ ដែលរៀបចំដោយគ.អ.ស.កក្នុងឆ្នាំ២០០៥

## កំណាព្យ ការជួញដូរកុមារ

បទពាក្យ៧

កុមារដែលគេជួញដូរគួរឱ្យអាណិត
កុមារខំធ្វើការមិនដែលរុញរា
ហេតុអ្វីឥឡូវមិនអាចបញ្ឈប់
វាយសុទ្ធតែដំបងឈើ
កុមារខំធ្វើរាល់កិច្ចការ
ខំតែរក្សាចិត្តដែលស្មោះ
ហេតុអ្វីធ្វើឱ្យចិត្តខ្ញុំលង់
មានតែពាក្យដែលជៀលត្មេះទេ

ផ្នែកខាងផ្លូវចិត្តក៏វេទនា
មានតែវេទនាគ្មានទីពឹង។
ឬមួយត្រូវស្លាប់ទើបឈប់ធ្វើ
ឬមួយចង់ធ្វើឱ្យជាតិស្លាប់។
តែគ្មានអ្នកណាមកជួយសោះ
គួរឱ្យស្រណោះចិត្តខំថៃ។
មានចិត្តសែនលុងជឿពាក្យគេ
កុមារទាំងអស់គួរតែចាំ៕

និពន្ធដោយ កុមារា ស៊ុន វីណា រៀនថ្នាក់ទី៥គ នៃសាលាសឿ ភូមិសឿ ឃុំសឿ ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ



គូរដោយ កុមារា ហាស់ វ៉ែន អាយុ១៦ឆ្នាំ មកពីអង្គការ SCADP ទទួលចំណាត់លេខ១ នៃការប្រលងគំនូរក្រុមកុមារអាយុពី១៦_១៧ឆ្នាំ ដែលរៀបចំដោយគ.អ.ស.កក្នុងឆ្នាំ២០០៥


### គណៈកម្មការពិនិត្យ

- លោក មាស សំណាង ប្រធាន គ.អ.ស.ក
- លោក ម៉ិច សុខា អនុប្រធាន គ.អ.ស.ក
- កញ្ញា លី សុទ្ធារី លេខាធិការ គ.អ.ស.ក
- លោកស្រី ថូ ថារី ហេរញ្ញិក គ.អ.ស.ក
- លោក ព្រំ ធី សមាជិក គ.អ.ស.ក
- លោក ស៊ុំ ចំរុង អគ្គលេខាធិការ គ.អ.ស.ក

### យកព័ត៌មាន និពន្ធ និងក្រាហ្វិកកុំព្យូទ័រ

- កញ្ញា ផ ស៊ីវហ្វយ អ្នកគ្រប់គ្រងព័ត៌មាន
- លោក ម៉ាន់ វ៉ាន់ផាន់និត ជាជំនួយការផ្នែកព័ត៌មាន

### បោះពុម្ពដោយ

គណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ

អាសយដ្ឋានទំនាក់ទំនង

ផ្ទះលេខ៨A ផ្លូវ១៣៨ សង្កាត់វាលវង់ ខណ្ឌ៧មករា

រាជធានីភ្នំពេញ

ទូរស័ព្ទ : (៨៥៥) ២៣ ៨៨២ ៤១២

អ៊ីមែល : ch.ngocrc@online.com.kh

### ឧបត្ថម្ភដោយ

Save the Children
Norway